## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

# សារលិខិតអបអរសាទរ

## សូមក្រាបបង្គំទូលថ្វាយ

## សម្តេចព្រះវ័នរ័ត មួង រ៉ា សម្តេចព្រះសង្ឃនាយករងទី២

## គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា

**សម្តេចព្រះវ័នរ័ត ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !**

ខ្ញុំព្រះករុណាខ្ញុំ និងភរិយា សូមសម្តែងនូវអំណរសាទរប្រកបដោយមនោសញ្ចេតនារីករាយឥតឧបមា ថ្វាយ **សម្តេចព្រះវ័នរ័ត ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ក្នុងឱកាសដែលសម្តេច ត្រូវបាន**ព្រះករុណាព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ប្រោស ព្រះរាជទានត្រាស់បង្គាប់ ដំឡើង និងតែងតាំងព្រះឋានៈជា **សម្តេចព្រះវ័នរ័ត ព្រះរាជាគណៈថ្នាក់ឯក សម្តេចព្រះសង្ឃនាយករងទី២ គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា**។

ព្រះគោរមងារ និងព្រះឋានៈថ្មីនេះ ពិតជាស័ក្តិសមបំផុតចំពោះ **សម្តេចព្រះវ័នរ័ត** ដែលមានស្នាព្រះហស្តកើតចេញពីព្រះសមត្ថភាព គុណបំណាច់ និងសមិទ្ធផលដ៏ថ្លៃថ្លានាពេលកន្លងមក ដោយបានបូជាកម្លាំងព្រះកាយពល និងព្រះបញ្ញាញាណ ក្នុងព្រះបុព្វហេតុជាឧត្តមប្រយោជន៍សម្រាប់ជាតិ និងក្នុងវិស័យព្រះពុទ្ធសាសនា។

នៅក្នុងវេលាកាសដ៏ថ្លៃថ្លាឧត្តុង្គឧត្តមនេះ ខ្ញុំព្រះករុណាខ្ញុំ និងភរិយា សូមលើកហត្ថបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាព្រះរាជាណាចក្រកម្ពុជា ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ សូមយាងអភិបាលបីបាច់ថែរក្សា និងប្រោះព្រំនូវសព្ទសាធុការពរ ប្រគេនចំពោះ **សម្តេចព្រះវ័នរ័ត ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមមានព្រះសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា រាងវៃ ព្រះជន្មាយុយឺនយូរ និងសមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះវ័នរ័ត ព្រះរាជាគណៈថ្នាក់ឯក សម្តេចព្រះសង្ឃនាយករងទី២ គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា** ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ចជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ពីខ្ញុំព្រះករុណាខ្ញុំ និងភរិយា។

ថ្ងៃចន្ទ ៩កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៤

**នាយឧត្តមសេនីយ៍ ទៀ ស៊ីហា**